# ជំពូក១

## សកម្មភាពនៃលោកសុគន្ធា

.....ព្រះអាទិត្យរះផុតជើងមេឃហើយ ប៉ុន្តែអ្នកស្រុកផ្សាររវៀង មើលពុំទាន់ឃើញពន្លឺចង្កៀងទិព្វនេះនៅឡើយទេ ដោយនៅជាយនៃទីប្រជុំជននេះ ព្រឹក្សាដ៏ខ្ពស់ៗដុះព័ទ្ធជុំវិញយ៉ាងក្រាស ។ គេហដ្ឋានជាច្រើនដែលស្មានថាតែពុំទាន់ភ្ញីនៅឡើយ ពុំព្រមបើកបង្អួចបើកទ្វារទេ ហាក់ដូចជានៅងងុយខ្លាំងណាស់ ។ ទុកជាខ្យល់បក់ពីទិសខាងជើងមកប្រានមែកឈើជិតខាង ឱ្យដាស់អង្រន់គេយ៉ាងណាក៏ដោយ ផ្ទះទាំងនោះខំប្រឹងសំងំស្ងៀម ដើម្បីផ្គាប់ចិត្តម្ចាស់គេរៀងខ្លួនដែលកំពុងនិទ្រាក្នុងភួយយ៉ាងក្រាស់លើគ្រែ ។ ខុសតែតែសាលាស្រុកមួយទេ ដែលមិនព្រមសុំចុះចាញ់ចំពោះធាតុរងាកំណាចក្នុងខែកក្តិកនេះសោះ ។ ទ្វារបង្អួចទាំងឡាយបើកចំហធំៗបង្ហាញកេសានៃមន្ត្រីគ្រប់រូបដែលកំពុងអង្គុយធ្វើការនៅតុរៀងខ្លួន ។ ពេលនោះពុំទាន់មានអ្នកស្រុកហ្វាក់ណាមកដល់ទេ ។ លុះត្រាតែសែងព្រះអាទិត្យនៃថ្ងៃច័ន្ទជ្រួតជ្រាបតាមចន្លោះតូចៗ នៃសន្លឹកឈើយ៉ាងក្រាស់ បញ្ចេញទិដ្ឋិភាពវែងៗដូចជាព្រួញស្វាបាញ់មកដោតនឹងជញ្ជាំងសាលា ទើបមានជនប្រុសស្រីបួនប្រាំនាក់ ដើរមកដល់ហើយបបោសជើងម៉ាខាងមុខសាលាអង្គុយស៊ីស្លាជក់បារី ។

– លោកចៅហ្វាយអញ្ជើញមកដល់ហើយឬនៅ ? (មនុស្សប្រុសម្នាក់ក្នុងចំណោមជនទាំងនោះកាន់ក្រដាសមួយមូរយ៉ាងតូច ដើរចូលមកហើយសួរបណ្ដូទូតម្នាក់ដែលអង្គុយនៅមាត់ទ្វារ មាត់ទ្វារនេះមានបិទបន្ទះក្ដារមួយសន្លឹកសរសេរដាក់ថា «ចៅហ្វាយស្រុក» ។

– មានការណ៍អ្វី? បើឡើងពាក្យប្ដឹងទេ សុំយកទៅជូនលោកស្មៀនសាលាឯណោះវិញ (បណ្ដូទូតឃាត់) ។

– ទេ ! ខ្ញុំមានការណ៍ធំណាស់ ចង់ជួបនឹងលោកចៅហ្វាយផ្ទាល់តែម្ដង ។

បណ្ដូទូតគោះទ្វារហើយនាំបុរសនេះទៅជួបលោកសុគន្ធាចៅហ្វាយស្រុករវៀងដែលអង្គុយនៅតុមួយធំម្នាក់ឯងក្នុងបន្ទប់យ៉ាងទូលាយ ។

– អញ្ជើញមកមានការណ៍អ្វីដែរឬ ? (លោកញញឹមសួរទៅអ្នកស្រុក ដែលធ្វើអាកប្បកិរិយាទ្រទន់ៗ សំពះប្រណម្យហុចពាក្យទៅលោកហើយ ដាក់ប្រាណអង្គុយចោងហោងទៅលើក្ដារ ដៃនៅតែប្រណម្យជាប់) ទេ ! ក្រោកឈរឡើងកុំធ្វើឯចឹងខ្មាស់ជាតិគេ អញ្ជើញអង្គុយនៅកៅអីនេះទៅ កៅអីនេះខ្ញុំទុកសំរាប់ឱ្យភ្ញៀវអង្គុយហើយ ។

.– ទានប្រោស ដូចជាពុំគួរបើនឹងអង្គុយស្មើនឹងព្រះតេជព្រះគុណម្ចាស់ៗ ជាចៅហ្វាយនាយយើងខ្ញុំ ។

– អ្នកយល់ខុសទេ (លោកចាប់ទាញដៃភ្ញៀវឱ្យអង្គុយលើកៅអី) កាលពីដើមខែនោះមែន សព្វថ្ងៃដែលប្រទេសយើងបានឯករាជ្យខ្លះហើយ



នេះ គេមិនប្រកាន់ដូច្នោះទៀតទេ យើងសុទ្ធតែជាអ្នកបំរើប្រទេសជាតិដូចគ្នា គ្មានអ្នកណាធំជាងអ្នកណាទេ...ឱ ! នេះពាក្យរបស់អ្នកឬ? ប្ដឹងពីចោរលួចគោ ? អ្នកនិយាយប្រាប់ខ្ញុំវិញពិស្ដារជាង ។

– ទានប្រោស ខ្ញុំបាទនេះហើយឈ្មោះ តា ចាន់នៅ ភូមិកំពង់ ពុទ្រាសូមទានកាលពីយប់ដប់បីរោជខែអាសាធនេះខ្ញុំបាទឃើញជាក់ជា ឈ្មោះពុទ្ធ-ជេស កាច់របារក្រោលចូលលួចគោខ្ញុំបាទពីក្រោមផ្ទះ មិនតែប៉ុណ្ណោះមានសាក្សីខ្ញុំបាទប្អូននាក់ដែលឮសូរបាក់របារ ក្រោកឡើង រត់មកទាន់ឃើញស្គាល់មុខវាច្បាស់ណាស់ ។

– វាចូលលួចពីពេលថ្មើម៉ាន ?

– ខ្ញុំបាទមិនដឹងម៉ោងទេ ប៉ុន្តែតាមចំណាំគឺពេលចាស់ដេកលក់ ។

– ចុះអ្នក ឬសាក្សីអ្នក មានកាន់ចង្កៀងឆ្នុះឬចន្លុះអ្វីទៅឈ្លបមើលទេ ?

– ទានគ្មានទេ ខ្លាចវាផ្អើល ។

– ចុះអ្នកឃើញស្គាល់អាចោរដោយសារពន្លឺអ្វី ?

– ទានលោកខែភ្លឺច្បាស់ ។

– កាលនោះវាលួចគោបានបេកទៅទេ ?

– ទានចឹក៏មិនបាន ។

– វាមានអាវុធទេ ?

– ទានគ្មានទេ ។

– ចុះសាក្សីអ្នក ដល់ទៅបួននាក់ទៅទាន់វាដែរម្ដេចក៏មិនចាប់វាឱ្យបានក្នុងពេលនោះទៅ ?

– ទានវារត់លឿនណាស់ តាមពុំទាន់ទេ វាដឹកគោឱ្យរត់តាមវាទៅ ។

– មើល ! អ្នកឯងអាងសាក្សីឈ្មោះអ្វី ?

– ឈ្មោះនាងទិត- ហ៊ុ ?

មួយរំពេជ តាមបង្គាប់លោកចៅហ្វាយស្រុក បណ្ដូទូតបញ្ចូលនារីម្នាក់កណ្ដាលមនុស្សស្លៀកសំពត់ខ្មៅពាក់អាវខ្មៅកាន់បង្វិចមួយនៅដៃ ។ ទាំងបបូរមាត់ទាំងធ្មេញខ្មៅយ៉ាងក្រាស់ហើយបៀមស្លាមួយម៉ាត់យ៉ាងធំ ។ នារីនេះមិនចាំសេចក្ដីបង្គាប់ទេ កាយវិការដំបូងបំផុតគឺទម្លាក់ខ្លួនអង្គុយបត់ជើងនៅក្ដារ ។ លោកចៅហ្វាយមើលឃើញមិនគប្បីក៏ចង្អុលបង្គាប់ឱ្យអង្គុយលើកៅអីវិញ ។ បានកៅអីហើយនៅលើកជើងបញ្ឈរជង្គង់លើកៅអីនោះទៀត ។ ទំរាំតែបានសួរចំលើយស្រួលបួលនោះ លោកចៅ-ហ្វាយខាតពេលអស់មិនតិច ។

– អ្នកឯងឈ្មោះអ្វី ( លោកសួរ)

– ខ្ញុំហ៊ឹះ ? ខ្ញុំឈ្មោះទិត ( នាងឆ្លើយតែប៉ុន្មានម៉ាត់នេះបណ្ដាលឱ្យលោកចៅហ្វាយធ្វើមុខជូរ ថ្វីបើលោកខំរក្សាទឹកមុខឱ្យនៅតែញញឹមដដែលក៏ដោយ) ។



សុំទោស អ្នកអញ្ជើញទៅក្រៅខ្ជាក់ស្លាខ្ពុរមាត់ចេញឱ្យស្អាតសិនសឹមចូលមក បើអ្នកនៅបៀមស្លាយ៉ាងនេះខ្ញុំស្ដាប់សំដីអ្នកមិនបានទេ ។

នាងទិតពុំទាន់ចូលមកវិញផង មានបុរសម្នាក់រុញទ្វារដើរទ្រទ្រ ចូលមកជួបនឹងលោក ។

លោកមេឃុំតែ្បង ឈប់សិន ! ខ្ញុំសុំរំពូកលោកបន្ដិចមុននឹងបើកឱ្យលោកនិយាយការនឹងខ្ញុំ សុំលោកកុំខឹងណ៎ះ! ឱនមកជិតខ្ញុំ ( លោកនិយាយតិចៗ) បើលោកចូលមករកខ្ញុំក្រោយៗ សុំគោះទ្វារសិន ចាំខ្ញុំស្រែកពីក្នុងថាឱ្យចូលសឹមចូល នេះបានគេហៅថាគួរសម ហើយមិនបាច់ដើរទ្រទ្រទេ ខ្ញុំសរប់ពកាស់ដើរតាមធម្មតាមក អ្នកដឹងទេ ? ប្រទេសគេជិតខាងគេដើរលឿនណាស់ទៅហើយ ដោយសារគេយកតម្រាប់តាមប្រទេសធំៗ រួចចុះលោកមេឃុំឯងមានការអ្វីទៅ ?

- ទានប្រោសពីយប់មិញមានចោរម្ភៃនាក់ កាន់កាំភ្លើងបួននឹងដាវកាំបិតគ្រប់ដៃ ចូលមកប្លន់ឈ្មោះ សុខ យកបានរបស់ទ្រព្យអស់រួមតម្លៃពីរពាន់រៀល ។ អ្នកស្រុកបានតាមទៅ ។ មិនទាន់ដោយវាចូលទៅក្នុងព្រៃខេត្តសៀមរាបហើយបាញ់ចំរុះមកអ្នកស្រុកវិញ ។

– វានៅម្ដុំណា ? មេឃុំឯងមានបានតាមទៅជាមួយនឹងអ្នកស្រុកទេ ? លោកមេឃុំឯងជូនខ្ញុំទៅ ។

លោកចៅហ្វាយហៅបណ្ដូទូតឱ្យអញ្ជើញលោកស្មៀនសាលាមកប្រគល់ការសួរចំលើយពីរឿងចោរលួចគោទៅស្មៀននេះ រួចហៅពូក

ភ្នាក់ងារប៉ូលីសប្រាំនាក់ឱ្យរៀបចំសេះនឹងសាស្ត្រាវុធទៅតាមចោរ ជាមួយនឹងលោកគ្មានបង្អង់ឡើយ លោកទុកតែដោយប៉ូលីសម្នាក់ឈ្មោះកញ្ចុះឱ្យនៅមើលសន្តិសុខក្នុងស្រុក ។

ថ្ងៃនោះលោកចៅហ្វាយអញ្ជើញទៅតាំងពីម៉ោងប្រាំបួនព្រឹក បាត់ទើសម៉ោងពីររសៀលទើបមកដល់ផ្ទះវិញ មានទាំងរទេះគោពីរមកជាមួយផង ។ រទេះមុខផ្ទុកសុទ្ធតែសំពត់អាវដែលរុំនឹងភួយ ជាបង្វេចយ៉ាងធំៗព្រមទាំងមានរបស់ឯទៀតជាច្រើន ។ ក្នុងរទេះមួយទៀតគេសង្កេតឃើញមានមនុស្សប្រុសបួននាក់អង្គុយបត់ជើង ដោយជាប់ចំណងស្ទាបសេករៀងខ្លួន ។





– លោកស្មៀនសាលាសួរចម្លើយព្រឹកមិញគ្រប់គ្នាអស់ហើយនៅ? (លោកសួរនៅពេលដែល លោកស្មៀនរត់ពីសាលាស្រុកសំដៅមកទទួលលោក) ។

– ទានប្រោស សួរគ្រប់គ្នាអស់ហើយ...ទានពិបាកសួរណាស់ ខ្ញុំបាទបានពិសោធមើលទៅ សាក្សីម្នាក់ថាដូច្នេះម្នាក់ថាដូច្នោះ (លោកស្មៀនសាលាស្រុកឆ្លើយហើយសាស័ព្ទឱ្យស្តាប់គ្មានចោលចំណុចណាមួយទេ) ។

– ន៎ ! ដូចខ្ញុំបានស្មានក្នុងចិត្តទុកមកដែរ ថាបណ្តឹងនេះជាការណ៍ពុំពិតសោះ សុំលោកព្រាងរាយការណ៍មួយប្តឹងទៅខេត្តតាមដំណើរខ្ចាស់ជាប់នូវពាក្យបណ្តឹងនឹងចំលើយទាំងអស់ទៅផង កុំភ្លេចបង្ហាញយោបល់យើងថា ព្រះចន្ទ្រដប់បីរោជគ្មានពន្លឺពីក្បាលព្រលប់ទេ ហើយធម្មតាចោរលួចគោ វេលាបើមានគេទាន់កាលណា វាតែងភៀសខ្លួនចោលគោនោះ ហើយមិនមែនដឹកជាប់ដៃវា ឱ្យគេតាមចាប់វាបានទេ រឿងនេះទៅជាអាចោរដឹកគោរត់យ៉ាងលឿន គេតាមចាប់វាពុំបាន ដូចជាជ្រុលខ្លាំងពេក។

– ចុះមនុស្សត្រូវចោទ ?

– ឱ្យវាទៅផ្ទះវិញចុះ គ្រាន់តែប្រាប់វាថាកុំឱ្យទៅណាឆ្ងាយចោលលំនៅ ក្រែងតុលាការត្រូវការរក ។ អើចឹងដោយ ! (លោកងាកទៅដោយកញ្ចុះដែលកំពុងឈរចាត់ការនាំពួកចោរដែលចាប់បានយកទៅឃុំ)

ចឹស្គាល់ឈ្មោះជេសនេះដែរ ? ទំនងជាមនុស្សចោរ ប៉ុន្តែគ្មានភស្តុតាងអ្វីនឹងបញ្ជូនទៅតុលាការសោះ ។

– ព្រះតេជព្រះគុណ ទើបនឹងផ្លាស់មកប៉ុន្មានខែនេះពុំទាន់ជ្រាបច្បាស់ទេ ( ដោយកញ្ចុះតប ) អាជេសនេះជាមេចោរលួចគោយ៉ាងធំណាស់ វាដើរលួចគោអ្នកស្រុកសឹងតែពាយអស់ទៅហើយ បើទុកឱ្យវានៅជាសុខតទៅទៀត ប្រហែលជា....

– វាលួចប្លន់អ្នកណាខ្លះពីមុនៗមក? ដោយប៉ូលិសនៅស្ងៀម ។ លោកចៅហ្វាយសុគន្ធាក៏ដើរមកគេហដ្ឋានលោកដែលនៅជាប់របងសាលាស្រុក ។

– ប៉ាទៅអីយូរម៉េះ ? ( នាងគន្ធពិដោរជាកូនក្រមុំលោកដែលឈរចាំលោកនៅមាត់ជណ្ដើរផ្ទះសួរ ) កូននឹងអ្នកដាយមិនទាន់ញ៉ាំបាយមួយមាត់ទេ អ្នកដាយគាត់អុចធូបបន់ព្រះសុំឱ្យប៉ាឯងមានជ័យជំនះ ឥឡូវមានមែនហ៎ុប៉ា ?

– មែនហើយកូន អាប្លននាក់នឹងហើយដែលប្លន់នៅឃុំត្បែងនោះ ( លោកប្រាប់កូននៅពេលដែលឡើងជណ្ដើរចូលទៅក្នុងផ្ទះ ហើយឃើញអ្នកស្រីប្រពន្ធលោកចេញមកទទួល )

ម៉ែអាដោម្ដេចក៏មិននាំកូនញ៉ាំបាយមុនទៅ ?

– អាដោវាមិនព្រម ( អ្នកស្រីតប ) ។



– ឃើ ! ឃើងដូចជាមានសំណាងដែរ ( លោកនិទានតបន្តិចៗព្រមជាមួយនឹងកាយវិការលោកដែលដោះសំលៀកបំពាក់ ហើយមកអង្គុយពិសាក្រយាហារ ) អាចោរបាញ់ផុតៗចុងត្រចៀក បើងាកក្បាលតែបន្តិចមកស្ដាំប្រហែលជាប៉ាមិនបានមកឃើញមុខកូនឯងក្នុងពេលនេះទេ អស្ចារ្យណាស់ម៉ែអាដោ បងមិនចង់និយាយទេ តែនិយាយឡើងម្ដងៗ វានាំឱ្យបងព្រឺសាច់ខ្លាក់ៗ មានស្រួលអ្វីវាៗពួនចាំមើលឯងៗអ្នកដើររកវា ក្នុងព្រៃងាយឯណានឹងរកវាឃើញ ត្រាតែវាបាញ់មកមុនទើបដឹងទីកន្លែងរបស់វា។

– ប៉ាអាដោឯងមិនត្រូវហ៊ានយ៉ាងនេះទេ ( អ្នកស្រីពោលបណ្ដើរយកចានពីលោកចៅហ្វាយទៅដួសបាយជូនលោកនឹងពិសាខ្លួនឯងបណ្ដើរ ) ស្លាប់ងាយណាស់ យើងធ្វើការតែល្មមៗបានហើយ រាជការធំលោកមិនមែនឃើញយើងធ្វើការយ៉ាងណាទេ ស្រុកដាច់ឆ្ងាយពីទីក្រុងយ៉ាងនេះផង បើនឹងបានសក្តិយសនោះមិនបាច់ខំឬច្រានទេ ។

– ម៉ែអាដោ យើងធ្វើការនេះមិនមែនប្រាថ្នាបុណ្យសក្តិសុទ្ធនោះទេ បើបងប្រាថ្នាយ៉ាងនេះបងមិនចាំបាច់សុំផ្លាស់មកស្រុកនេះរកស៊ីលក់ស្បែក នឹងឆ្អឹងបងទេ បងនៅតែស្រុកជិតៗព្រះរាជធានីទៅក៏គង់បានបុណ្យសក្តិដែរ ប៉ុន្តែអូនគិតមើលផងរាស្ត្រស្រុកនេះវេទនាយ៉ាងណា? តាំងពីរាជស្ដេចអង្គណាមកក៏មិនដែលបានយល់សេចក្ដីសុខចំរើនសោះ បើមិនត្រូវចោរព្រៃប្លន់ដណ្ដើមយកទ្រព្យសម្បត្តិទេ ក៏ត្រូវអ្នករាជការរឹបជាន់អូសដីភូមិស្រែចំការ រីឯអារ្យធម៌វិញគឺ «សូន្យ» គ្មានឃើញលូតលាស់ត្រង់

ពោកបានបន្ថែមសោះ បងតូចចិត្តណាស់កាលបើឃើញទស្សនីយភាពដ៏អកុសលបែបនេះ គិតថាគេក៏ខ្មែរ ឯងក៏ខ្មែរ ខ្មែរដូចគ្នា ខ្មែរត្រូវស្លាប់ជាតិ-ខ្មែរផង់ ឱ្យខ្មែរបានរុងរឿងចេះដឹងស្មើៗគ្នាឡើង...

# ជំពូក២

## មហន្តរាយ

ក្នុងមួយថ្ងៃនេះ តាំងពីព្រឹកទើសល្ងាចលោកសុគន្ធាគ្មានពេលទំនេរមួយវិនាទីណាឡើយ ។ បើមិនចេញទៅបង្ក្រាបសត្រូវទេ ក៏លោកនៅតែនឹងមន្ទីរធ្វើការរបស់លោក ដើម្បីទទួលភ្ញៀវដែលមកថ្លែងទុក្ខព្រមទាំងជំនុំជំរះការវិវាទទាំងឡាយ លោកមិនចេះធុញទ្រាន់នឹងបណ្ដារាស្ត្រដែលមករកលោកខុសម៉ោងពេលទេ ។ ពេលល្ងាចសោតទុកជារនាំងខ្មៅនៃរាត្រីទំលាក់មកបាំងទេសភាពនានាក៏ដោយបើជានៅសល់ការច្រើនទៀត លោកសុំទ្រាំបង្អើយការនោះ ឱ្យអស់សិនទើបវិលមកផ្ទះរកបាយទឹក ។

ក្នុងរាត្រីថ្ងៃនេះ លោកអស់កំលាំងពេកណាស់រកគាន់ផងបាកកាក្រដាសព្រាងរាយការណ៍ដូចសព្វមួយដងពុំបាន ។ ពោមួយធាតុរងាដែលខ្យល់ផ្ញើពីក្រៅវ៉ូៗ គ្មានឈប់ឈរនោះ ជ្រាបចុលក្នុងផ្ទះតាមស្លាបព្រឹលនឹងចន្លោះក្ដារជញ្ជាំងមករំពល់ទុក្ខលោករកអង្គុយលេងផងពុំបាន ។

អាដោ នាំប្អូនទៅគេងទៅ ៎ លោកប្រាប់ពីគ្រែលោកទៅកូនស្រីលោក ដែលអង្គុយដេរនៅជិតចង្កៀងប្រេងកាត់ នៅផ្ញើអ្វីទៀត ផ្ទះគេក៏ដេកស្ងាត់អស់ទៅហើយ ។

– អើប៉ាអាដោ យើងគិតម្ដេចទៅ ? អ្នកស្រីដែលសំរាន្តនៅជិតនឹកភ្ញាក់សួរលោក នៅពេលដែលកូនស្រីលោកចូលទៅក្នុងបន្ទប់ផុតទៅ៎

ត្បិតពីថ្ងៃមិញថីដោយកញ្ចុះបានមកសួរបញ្ជាក់យើងម្តងទៀតហើយ ។

– បងគិតស្រេចហើយអូន ព្រោះបងបានឱ្យគេស៊ើបមើលទៅឃើញថាមិនកើត ។ ម្តេចក៏ថាមិនកើត ? ចៅក្លាញកូនគាត់នោះបងបានឃើញហើយកាលវានៅតូចនោះវាសុភាពមែនហើយ ដល់មកឥឡូវ៉ះដោយខ្លួនទៅវិញ តាំងពីវាបានធ្វើការមានសក្តិយសបានប្រាក់ខែនេះ វាភ្លើនហួសមាឌ សឹងចង់ជាន់ក្បាលគេទៅទៀត បងស្អប់ណាស់មនុស្សណាដែលដើរផ្ទុយនឹងគោលបំណងរបស់បង ។

– ហ្អឹង ! បងឯងចង់ឱ្យអាដោទៅតិញហើយហ្អឹង ខ្ញុំស្អប់ណាស់កំពូជតិញ ។

– បងមិនគិតទេ ក្រមការក៏ដោយ តិញក៏ដោយ ទាហានក៏ដោយ ឱ្យតែមនុស្សនោះដឹងឆ្វេងស្តាំចេះគិតដល់សុខទុក្ខរបស់ជនជាតិខ្មែរគ្នាឯង មិនរាប់មានក្រ ដូចជាកាលគេមកនិយាយលើកមុន បើសិនជាបងស៊ើបទៅត្រូវចិត្តបង១ ឱ្យគេភ្លាម ថ្វីត្បិតតែធ្វើតិញ១ ពុំមែនសុទ្ធតែអាក្រក់ទាំងអស់គ្នាទេ ប៉ុន្តែបងស្តាយណាស់ពុំទាន់បានស៊ើបដឹងការអ្វីផងអូនឯងប្រញាប់ទៅបណ្តេញគេឱ្យថយចេញទៅ ។

– ណ្ហើយបងអើយ ! ឱ្យអាដោទៅកូនថីដោយកញ្ចុះទៅអាហេិតគាត់១ តាមអង្វរយើងញឹកណាស់ មួយទៀតគាត់ជាមនុស្សស្មោះត្រង់នឹងយើង គាត់ធ្វើការនៅស្រុកនេះយូរឆ្នាំមកហើយ ឮតែគេសរសើរថាជាមនុស្សល្អ គួរឱ្យគាត់សប្បាយចិត្តម្តងទៅ មួយទៀតទុកជាកូនគាត់មានកិរិយាយ៉ាងណាក៏ដោយ ក៏គង់ថ្កើងមុខកូនស្រីយើងដែរ យើងធ្វើការ



ប៉ុណ្ណេះដែរឱ្យកូនទៅមនុស្សមិនសមសក្តិដូចជាមិនល្អ ហើយគេសើចយើងណាបង ។

– អូន ! បងបានប្រាប់អូនឯងរួចហើយតើ ថាបងមិនព្រមឱ្យទេ ដោយកញ្ចុះនោះក៏បងបាននិយាយប្រាប់វាហើយដែរម្តេចក៏វានៅតែទទូចសួរច្រំដែល១ទៀត ?

និយាយគ្នានេះពុំបានគិតដល់ពេលម៉ោងទេ តាមតែនាឡិកាដែលព្យួរនៅជញ្ជាំងសាលុងវាយម៉ោង៨-៩-១០ បន្ត១គ្នាតែវាទៅចុះ លុះត្រាតែមានសូរកាំភ្លើងផ្ទុះពីចម្ងាយមកឮតែប៉ក១ប៉េវ! ប៉កប៉េវក្តុង ហើយឮសូរកាំភ្លើងពួកប៉ូលិសសាលាស្រុកបាញ់តទៅវិញផង ទើបលោកសុគន្ធាស្ទុះក្រោកឡើងកញ្ឆក់បានចង្កៀងពិលនឹងកាំភ្លើងយន្តតូចដែលដាក់ជិតខ្លួនជាអលជ្ជី លូន១ សំដៅទៅទ្វារ ប៉ុន្តែលោកមិនទាន់បើកទេចាំស្តាប់ជើងការសិន ។ មិនយូរប៉ុន្មានលោកឮសូរជើងមនុស្សពីរនាក់ជព្រួំជណ្តើរមុខផ្ទះឡើងមកហើយខ្សិបហៅ :

– ព្រះតេជគុណេ !១ !

– ...(លោកចៅហ្វាយនៅស្ងៀមព្រោះមិនទាន់ស្គាល់មាត់) ។

– ព្រះតេជគុណម្ចាស់ ! ពួកចោរចូលលុកប៉ុស្តិ៍ហើយ ។

– អ្នកណា ? ថីដោយកញ្ចុះនឹងក្រាញ់ឬ? ថីឯងបានរៀបចំឱ្យការពារស្រួលបួលហើយឬនៅ ?

– ទានរួចស្រេចហើយ ប៉ុន្តែ....

លោកសុគន្ធារកប្រាប់ប្រពន្ធឱ្យដាស់កូនរៀបចំរកកន្លែងជ្រកពួនពុំទាន់ផង មានសូរមនុស្សជាច្រើនស្រែកសន្ធាប់ឡើងថា «ចាប់ៗ ! ព័ទ្ធៗ!» ទ្រហឹងជុំវិញតែគេហដ្ឋានលោកៗ បើកទ្វារបញ្ចាំងពិលទៅ ឃើញសុទ្ធតែមនុស្សស្លៀកពាក់កាតិ ជូតក្បាលកន្សែងពោះគោរត់សំរុកចូលតាម



ទ្វាររបងសាលាស្រុកមករាប់រយនាក់ គ្មានរវល់គិតអំពីពួកប៉ូលិសបាញ់វា



យ៉ាពោះឡើយ ។ ហើយពួកប៉ូលិសបាញ់ទៅដូចជាគ្មានត្រូវពួកវាម្នាក់ពោះសោះ បើថាពួកវាខ្លាំងពូកែបញ្ចៀសគ្រាប់ដោយមន្តគាថាទៅក៏សឹងតែបាន ។ លោកចៅហ្វាយសោតទាញកែកាំភ្លើងយន្តផ្ទុះគ្រាប់ឡើងឮប៉ុនព្យុះក៏វាគ្មានតក់ស្លុតបន្តិចសោះ ។ ដោយប៉ូលីសទាំងពីរនាក់ចោលគ្រាប់បែកដៃទៅ ផ្ទុះបែកឡើងសឹងដាចក្រដាសត្រចៀករងៀងខ្លួន ក៏ពួកនោះនៅតែដើរសំរុកចូលធ្វើហី គ្មានគ្រោះថ្នាក់អ្វីដល់ខ្លួនពួកវាសោះ ។ លោកស្រែកអោយប៉ូលីសភាសខ្លួនជាប្រញាប់ ចំណែកលោកៗថយចូលមកក្នុងផ្ទះបិទទ្វារខ្ទាស់ជាប់ ហើយរត់ទៅរកប្រពន្ធនឹងកូនធំតូច លោកទាញយកកាំភ្លើងស្នៀតរបស់លោកកាន់នៅដៃតាមទំលាប់ ។ ក្នុងពេលភ្លាមៗនោះមានសូរមាត់ពួកវាសន្ធាប់នៅជុំវិញផ្ទះលោកថា «យកក្បាលវាឱ្យបានរើយ» ឬ «ជយោ! ជយោ!» ។ វាស្រែកផងពុះទ្វារទាំងមុខទាំងក្រោយផង ប៉ុន្តែលោកសុគន្ធាមិនស្លុតទេ ព្រួយបារម្ភតែអំពីជោគ-វាសនានៃកូនប្រពន្ធ ដែលនឹងផុតជីវិតនៅនឹងភ្នែកលោកឡូវនេះប៉ុណ្ណោះ។ ដើម្បីនឹងធ្វើគារវកិច្ចចំពោះ ពេលក្រោយបំផុតក្នុងអាយុជីវិត លោកៗលើកដៃស្តាំដែលកាន់កាំភ្លើងស្នៀតឡើងលើ ស្រែកអស់ទំហឹងថា «ជយោ! ព្រះមហាក្សត្រខ្ញុំ» ក្នុងពេលនេះហើយដែលពួកចោរពុះទ្វារក្រោយរបើកចូលមកបានដល់ក្នុងផ្ទះម្តងម្នាក់ៗ ។ លោកចៅហ្វាយដឹងថា ឫទ្ធិពួកចោរខ្លាំងពូកែជាក់ស្តែងមែនហើយទទួលលោកគិតថា បើលោកនឹងស្លាប់ជាក៏ឱ្យបានតស៊ូនឹងវាឱ្យអស់ដៃសិនដែរ លោកតម្រង់ មាត់ត្រៃកាំភ្លើងស្នៀតលោកទៅពួកខ្លាំងហើយកេះកៃទៅ ស្រាប់តែពួកចោរដែលចូលដល់ក្នុងផ្ទះ

លោកដួលគ្មោល១ ពីរបីនាក់ដាច់ខ្យល់ដោយ សារគ្រាប់នៃអាវុធតូចនេះ ។ លោកស្ទុះទៅពួននៅកៀនទូដែក បាញ់ថែមទៀត ដោយពួកវាបាញ់តមក គ្មានឈប់ឈរបាញ់ទៅបាញ់មកមួយភ្លែតស្រាប់តែ មានអាម្នាក់ប្រថុយស្លាប់រត់មកចាប់នាងពិដោរពីក្រោយ ទាញនាងឱ្យទៅឈរពាំងនៅមុខពួក





វា១នឹងពួនពីក្រោយនាង ដើម្បីបាញ់តាមកលោកដោយងាយ។ លោកសុគន្ធា ទំលាក់កាំភ្លើងចុះលើកដៃទាំងពីរ ឡើងតាមបង្គាប់ពួកវា ដោយលោក រកបាញ់តទៅទៀតពុំកើតខ្លាចត្រូវ កូនស្រីសម្លាញ់លោក ។ ប៉ុន្តែលោកមិន ចាំឱ្យវាចាប់លោកបានទាន់ទេ លោកលោតផ្លោតទៅតាមបង្អួចដែលមាន ពួកវាចាំប្រុងឯដីនោះស្រាប់ ។ កាំភ្លើងពួកវាឯដីផ្ទុះឡើងផ្ទូង ហើយសម្លេង ពួកវាម្នាក់បន្លឺឡើងថា ឱ្យឯងទៅណារួច? ពួកយើងមកសែងយកខ្មោច អាកំបុតកនេះទៅធ្វើបុណ្យឱ្យវាឯជំរុំយើងទើបសមសក្តិវា ។

តែប៉ុណ្ណេះសូរកាំភ្លើងក៏អន់ថយទៅវិញ ។ លុះស្ងប់ស្ងាត់អស់ ហើយអ្នកស្រុកដែលបានរត់ពួនដោយតម្កោតព្រៃទាំងប៉ុន្មាននៅមាត់ថ្កល់ ទៅលិចបានសង្កេតឃើញពួកអាចោរនាំគ្នាដើរជាជួរចេញពីសាលាស្រុក មកដោយប៉ោកព្រហ្សរីអឹងអាប់ គ្មានភ័យនឹងអ្វីទៀតសោះ គ្នាវាបួននាក់សែងគ្រែស្នែងមួយដែលមានរូបមនុស្សម្នាក់ដេកស្តូកគ្មានកំរើកសោះ ។ នៅអមគ្រែស្នែងនេះ ពួកចោរកាន់កាំភ្លើងដើរធ្វើឫកសំបើម ។ នាងគន្ធពិដោរយំទួញពីក្រោយរាប់រៀបសព្វគ្រប់ ។

ពួកអ្នកស្រុកផ្សាររវៀងទាំងឡាយ គ្មាននរណាហ៊ានហើបមាត់បន្តិចទេ ព្រោះគ្មានកាំភ្លើងដើម្បីតស៊ូនឹងពួកវាដែលមានអាវុធនេះគ្រប់ដៃ ហើយដែលមានជ័យជំនះលើលោកចៅហ្វាយស្រុកផង ។ គេចាំមើលតែពួកចោរចេញផុតទៅអស់ហើយ ទើបនាំគ្នាអុចចន្លុះព្រោងព្រាតដើរ

មកបំភ្លឺមើលទីកន្លែង ។ គេប្រទះឃើញពួកភ្នាក់ងារប៉ូលិសសាលាស្រុកត្រូវគ្រាប់ដេកស្តូកដោយដីបីនាក់នៅនឹងប៉មដែលយាមច្រកមុខបីនាក់ទៀតនៅនឹងប៉មចំហៀងខាងជើង ។ ពួកប៉ូលិសឯទៀតមិនដឹងជាទៅណាបាត់អស់ទេ គេគ្មានឃើញខ្មោចពួកចោរសោះ ក្រៅពីបួននាក់ដែលលោកចៅហ្វាយបាញ់ត្រូវនៅលើគេហដ្ឋានលោក ។ មានទស្សនីយភាពមួយគួរឱ្យរន្ធត់ដល់អ្នកដែលមើលឃើញដំបូង ។ គឺអសុភអ្នកស្រីប្រពន្ធលោកសុគន្ធាដែលត្រូវគ្រាប់នៅទ្រូងខាងឆ្វេងស្លាប់នៅមាត់ទ្វារបន្ទប់ ឈាមហូរហៀរទៅលើក្តាក្រាលជាមួយនឹងអសុភកូនប្រុសតូចពីរនាក់ មួយអាយុបួនឆ្នាំមួយទៀតទើបតែនឹងបានជាងមួយខួប ដែលត្រូវពួកចោរចាក់ម្នាក់មួយកាំបិតស្បៀត ។ នេះបើលោកសុគន្ធាបាននៅឃើញផងមិនដឹងជាលោកសោកសង្រេងយ៉ាងណាទៅទេ ។ ឯចោរប្លន់បួននាក់ដែលលោកសុគន្ធាចាប់បានមកពីថ្ងៃនោះ ក៏មិនដឹងជាទៅណាបាត់ ។ គេឃើញតែទ្វារគុកនៅចំហរផ្លូង ។

*****

# ជំពូក៣
## ប្រតិបត្តិការឥតផល

ព្រឹកឡើងលោកស្មៀនសាលានឹងលោកយោក្ស័ត្រទាំងឡាយ នាំគ្នាដើរពិនិត្យភិនភាគទីកន្លែងនឹងភិនភាគអសុភសព្វគ្រប់ ព្រមទាំងប្រមូលភស្តុតាងដាក់មុំ ដើម្បីធ្វើសេចក្តីកត់ហេតុប្តឹងទៅរាជការធំ ។ ប៉ុន្តែលោករកពត៌មានអ្វីអំពីការប្រយុទ្ធនេះដ៏ពិស្តារពុំបានសោះ ព្រោះកាលពីយប់មិញនោះលោកនៅនឹងផ្ទះរៀងខ្លួន ឮតែសូរផ្ទួងផាំងបាញ់ទៅបាញ់មកប៉ុណ្ណោះ គ្មាននរណាម្នាក់នឹងសួរយកការណ៍បានឡើយ ។ មួយទៀតនឹងរកនរណាដ៏អង់អាច នាំដំណឹងអំពីភយន្តរាយនេះទៅសាលាខេត្តកំពង់ធំក៏ពុំបានផង ព្រោះយល់ថាពួកចោរដែលមានជ័យជំនះដូច្នេះវាមុខជានឹងរាយអំណាចវាពាសពេញផែនដីជាមិនខាន ។ ស្រុករវៀងទាំងមូលនេះមុខជាវាត្រួតត្រាពេញទី ។ មន្ត្រីសាលាស្រុកទាំងប៉ុន្មាន អ្នកប្រុងចុះគ្មាននរណាការពារអ្នកទេ តាមសព្វមួយដងបើលោកចៅហ្វាយមានការអ្វីទាក់ទងនឹងសាលាខេត្ត ដែលនៅចម្ងាយប្រហែលប៉ែតសិបប្រាំគីឡូម៉ែត្រពីគ្នា លោកតែងប្រើតែថីដោយក្រាញ់ជិះសេះទៅម្នាក់ឯង ឬជាមួយភ្នាក់-ងារប៉ូលីសម្នាក់ទៀតបានហើយ ព្រោះថីដោយក្រាញ់ជាមនុស្សជំនាញហើយក្លាហានណាស់ ។ ចុះឥឡូវថីដោយក្រាញ់ក៏មិននៅថីដោយកញ្ចុះក៏មិននៅ ។ សូម្បីតែភ្នាក់ងារប៉ូលីសណាម្នាក់ក៏គ្មានផង តើប្រើនរណា

បាន ? ។ ទាំងអស់គ្នាកំពុងបារម្ភដូច្នេះ ស្រាប់តែឮសូរសន្ធឹកយន្ត នឹងឃើញរថក្រោះបី បរពីមុខកាម្លុងធំៗ ប្រាំមួយដែលផ្ទុកសុទ្ធតែទាហានដែលកាន់កាំភ្លើងនឹងមានគ្រឿងយុទ្ធភ័ណ្ឌឯទៀតគ្រប់មុខ ។ កាលបើយានទាំងនេះមកដល់មុខសាលាស្រុក គេឃើញលោកភូឈួយខេត្ត លោកមេបញ្ជាការក្រុមទាហានថ្មើរជើង លោកកុម្មីស្សែរប៉ូលិសជាតិ លោកព្រះរាជអាជ្ញាសាលាដំបូង នឹងលោកគ្រូពេទ្យ ជាមន្ត្រីចៅក្រសួង នៅខេត្តកំពង់ធំ ចេញពីរថក្រោះមក ដោយមានស្មៀនសមុហបញ្ជីភ្នាក់ងារ ប៉ូលិសជាតិ នឹងតិលានុបដ្ឋាកអមផង ។ គេឃើញចុះមកមុនគេបំផុតគឺ ដោយក្រាញ់ ។

– ខ្ញុំបាទយប់មិញថាតែស្លាប់ហើយតើ ( ដោយក្រាញនិយាយប្រាប់





លោកស្មៀនសាលានឹងយោក្ស័ត្រ ដែលបើកភ្នែកធំៗឆ្ងល់) ដូចជាមិនដែលឯចឹងសោះ គួរក្ដៅក្រហាយពេកណាស់ ធ្លាប់មានថ្វីដៃនឹងគេដែរបែរជាចាញ់ដៃវាស្រឡះយ៉ាងនេះ ។ មន្តអាគមអីវាក៏ខ្លាំងដៃម្ល៉េះ ? បាញ់វាយ៉ាងណាក៏ពុំមុតវាសោះ ។ ខ្ញុំនឹងឋិដោយកញ្ចុះបានរត់ឡើងទៅដាស់លោកចៅហ្វាយ ហើយបានបាញ់នឹងវាបានបន្តិចមើលទៅធ្វើវាមិនរបើកក៏ភៀសខ្លួនបោលចូលក្នុងហ្វូងវាប្រថុយស្លាប់ ។ ប៉ុន្តែវាពុំបានធ្វើអ្វីខ្ញុំទេ ប្រហែលជាវាកំពុងមានចិត្តត្រង់គេបាញ់វាមិនមុតឬមួយក៏កំពុងតែខំស្រែក ជយោ! ជយោ! ចិត្តបាញ់ស្នៅទៅតែលោកចៅហ្វាយជាកំពូលទេដឹង ? ផុតពីហ្វូងពួកវាកាលណា ខ្ញុំគិតតែពីលូនមកខាងត្បូងជាងពីររយម៉ែត្រ ពុំដឹងជាវាចាប់លោកចៅហ្វាយបានដែរឬទេ ពុំដឹងជាវាសម្លាប់លោក ឬឈ្មោះណាខ្លះទៅហើយទេ ។

លោកយោក្ស័ត្រចូលទៅទទួលអស់លោកអ្នកធំៗ

ងដោយក្រាញ់ និយាយជំរាបលោកស្មៀនសាលាទៅទៀត

សំពោងបណ្ដោលឱ្យខ្ញុំនឹកឃើញថា ជុំះដង្ហៅឌុសឈ្មោះប៉េងអាងនេះសេះមួយ ខ្ញុំចូលទៅឃើញសេះនៅទីរក្រោល ខ្ញុំក៏លួចយកសេះនោះបោលក្នុងទៅ ។ បំបោលសេះនេះទាំងយប់តម្រង់ទៅទិសខាងត្បូងដោយមើលផ្កាយ ប្រាថ្នាមកប្ដឹងចៅហ្វាយម្ចាស់ខេត្ត ។ ជិះកាត់ព្រៃផ្សៃរហូត ចំនួនពីរម៉ោងទើបបានខ្ញុំមកប្រទះថ្នល់ ដែលមកពីកំពង់ត្របែក ។ បានផ្លូវស្រួលយ៉ាងនេះហើយខ្ញុំគិតតែពីបំបោលសេះតាមថ្នល់គ្មានរវល់នឹងផ្លែនៃភូមិជិតខាងថ្នល់ព្រុសដេញយ៉ាងណាសោះ ។ លុះត្រា

តែថ្ងៃរះទើបខ្ញុំទៅដល់កំពង់ធំ ។ ចៅហ្វាយម្ចាស់ខេត្តក៏ចាត់ការរហ័សទាន់ចិត្តណាស់ ។ យើងចេញពីនោះមកម៉ោងប្រាំពីរកន្លះ មកដល់នេះម៉ោងប្រាំបួន ។ តាមផ្លូវយើងគ្មានបង្អង់ទេ សុទ្ធតែពីជាន់វ៉ាអស់៧ខ្យល់ ។

នៅពេលដែលរាជការស៊ីវិលកំពុងស៊ើបអង្កេតដល់បណ្ដាជនក្នុងស្រុកនឹងបំពេញករណីយកិច្ច តាមការមុខក្រសួងរៀងខ្លួន ដោយប៉ូលិសក្រាញ់នាំពួកកងទ័ពបររថក្រោះនឹងកាម្នុង ចេញទៅតាមដានពួកចោរ ។ ពួកទ័ពបានបំបែកគ្នាទៅត្រង់ថ្នល់ខ្វាវ ដែលទៅកាន់ប្រាសាទបេងមាលាមួយកងទៀតបែកទៅទិសខាងជើង កាត់ភូមិត្បែងនឹងភូមិសំឡន ។ មានមួយកងទៀតចេញពីផ្សាររវៀងទៅទិសឥសានសំដៅទៅភូមិកំពង់-ពុទ្រា ។ បានជាបំបែកគ្នាដូច្នេះព្រោះមិនទុកចិត្តអ្នកស្រុកដែលឱ្យការស្មាក់ស្មើរដោយខ្លាចពួកព្រៃនឹងសងសឹក ។ ពួកទ័ពទាំងបីកងនេះបរយានតាមផ្លូវថ្នល់ហើយបាញ់នឹងកាំភ្លើងយន្តរៈបោសពេញព្រៃសងខាង ។ បើជាមានអ្នកស្រុកណាសុចរិតដើររកឃ្មុំ ឬរកឧសប្រហែលជានឹងត្រូវគ្រាប់ជាមិនខាន ។ ប៉ុន្តែថ្វីបើធ្វើសំបើមអស្ចារ្យយ៉ាងនេះក៏ដោយ ការតាមរកនេះនៅតែគ្មានបានលទ្ធផលអ្វីសោះ ។ មានតែពួកកងទីពីរដែលទៅទិសខាងជើងទេដែលបានប្រយោជន៍បន្តិចបន្តួច ព្រោះកាលបើទៅដល់ជើងភ្នំត្បែង ជិតភូមិសំឡន កងនេះបានប្រទះឃើញដោយប៉ូលិសកញ្ចុះចេញពីព្រៃមកធ្វើអកប្បកិរិយាភ័យស្លន់ ស្រែកហៅពួកទ័ពឱ្យជួយ បើកុំតែដោយក្រាញ់ដែលជិះយានមុខឃើញស្គាល់មុខ កុំអីត្រូវពួកទាហានបាញ់ចោលទៅហើយ ។





– ពួកវាទៅតាមថ្នល់ តម្រង់ទៅកោះកែរហើយ វាថាជុំវ៉ាទៅម្តុំប្រាសាទកោះកែរ (ដោយកញ្ចុះនិយាយប្រាប់ហើយបង្ហាញស្លាកស្នាម) មើលកដៃខ្ញុំនេះចុះ វាចងស្ទាបសេកទៅក្រោយ ថាវាធ្វើយ៉ាងនេះគឺសងសឹកគ្នាវាដែលលោកចៅហ្វាយចាប់បានពីថ្ងៃម្សិលមិញ នេះខ្ញុំភៀសខ្លួនពីកណ្ដាប់ដៃវាបាន ហើយនឹកភ័យថាមើលទៅប្រហែលជាទៅស្រុកវិញពុំដល់ទេ ខ្លាចក្រែងគ្នាវាចាប់បានបញ្ជូនទៅឱ្យវាទៀត ឱ! នេះគឺផលបុណ្យខ្ញុំពីជាតិមុនលោក ជូនខ្ញុំឱ្យបានមកជួបនឹងពួកទ័ពអស់លោកនេះ ។

– ម្ដេចទៅ? លោកចៅហ្វាយយើង វាយកទៅតាមវាឬមួយក៏លោករត់រួចដែរ ? (ដោយក្រាញ់សួរ) ។

– គ្មានផ្លូវទេ លោកចៅហ្វាយស្លាប់ដោយត្រូវគ្រាប់របស់វាតាំងពីនៅផ្ទះលោកម្លេះ វាបានដាក់លោកលើគ្រែស្នែងហើយសែងយកទៅជុំវាៗ ថាយកទៅធ្វើបុណ្យសម្ពោធិ៍លោកចៅហ្វាយស្រុកថ្មីដែលមានថ្វីដៃខាងបង្ក្រាបចោរកម្ម ។ វាមានទាំងចាប់កូនក្រមុំលោកទៅជាមួយផង..

– មកឡើងមក ! យើងទៅតាមវាឱ្យទាន់ មិនជាឆ្ងាយប៉ុន្មានទេ ។

ក្បួនយាននៃទ័ពរាជការ ខេត្តកំពង់ធំទៅតាមផ្លូវរហូតដល់ភូមិសំឡូន ពុំឃើញមានអ្វីក៏ហួសទៅទៀត ។ ពួកនេះខំស្រូតលុះត្រាតែដល់ប្រាសាទ ឱកោះកែរដែលព្រះបាទជ័យវរ្ម័ទី៤ បានសាងពីក្នុងរវាងគ្រិស្តសករាជ ៩២៨ ទៅ ៩៤២ ។

នាយទាហានបានឱ្យបញ្ជាការបង្គាប់ទៅពួកក្រោមឱ្យដើរលុកព្រៃឆែកឆេររកសំបុកចោរប៉ុន្តែគ្មានឃើញចោរណាសោះ បែរជាទៅឃើញឯក្របីព្រៃទៅវិញ ។ គេបាននាំគ្នាបាញ់ក្របីព្រៃមួយសែងយកមកពន្លះសាច់ដុតចែកគ្នាក្លែមស្រា ។ រួចគេបាយទឹកពេលថ្ងៃត្រង់ ក្រោមម្លប់ព្រឹក្សាខាងលិចប្រាសាទវត្តនេះទៅ ។ លុះបានសើុបដល់អ្នកស្រុកជិតខាងប្រាសាទនោះទៅពុំបានការអ្វី ដោយអ្នកស្រុកទាំងអស់ប្រាប់ថា មិនឃើញពួកចោរក្រុមណោដើរមកដល់ទិនេះទេ ហើយបើនឹងធ្វើដំណើរតទៅទៀតឃើញថាទៅពុំកើត ព្រោះស្ពានទាំងឡាយបានអន្តរាយខ្ទេចខ្ទីតាំងពីមានអសន្តិសុខមកម្លេះ ពួកកងទាហានក៏នាំគ្នាត្រឡប់មករវៀងវិញតាមមាគ៌ាដដែល ។



ក្រោយដែលយកចម្លើយដោយប៉ូលីសក្រាញ់នឹងដោយកញ្ចុះរួចហើយៗ ក្រោយដែលលោកគ្រូពេទ្យបានវះកាត់ឆែកឆេររកហេតុផលនៃរបួសដែលនៅនឹងរូបអសុភ ទាំងឡាយនោះ ពួកអ្នកជំនាញខាងក្រសួងសុីវិលក៏បានបង្ហើយសេចក្ដីកត់ហេតុរៀងខ្លួន ព្រមទាំងបានប្រមូលរបស់តាងដូចជាសំបកគ្រាប់កាំភ្លើង កាំបិតស្នៀត ដាវ ដែលជ្រុះនៅដីកាលកើតហេតុជាដើម ។ កំណត់ហេតុទាំងអស់ជូនយោបល់ប្រហែលៗគ្នាថាពួកចោរដែលមានចំនួនមនុស្សច្រើនលើសលុបនឹងមានមន្តអាគមខ្លាំងពូកែពិតមែននោះបណ្ដាលឱ្យលោកសុគន្ធា នឹងប៉ូលីសចាញ់ដៃវាដោយងាយ ។ គេបញ្ជាក់តាមចម្លើយអ្នកស្រុករវៀងគ្រប់មាត់ថា លោកសុគន្ធានេះជាមន្ត្រីម្នាក់ធ្វើការស្មោះត្រង់នឹងប្រទេសជាតិមាតុភូមិរបស់ខ្លួន ។ ថាលោកមានចិត្តចង់អប់រំបណ្ដាជន ដែលនៅឆោតល្ងង់ឱ្យទៅកាន់អារ្យធម៌តាមរបៀបប្រទេសឯករាជ្យ ។ លុះមន្ត្រីទាំងនេះបានត្រួតត្រាការធ្វើបុណ្យរំលាយសពនៃពួកប៉ូលិសរួចហើយគេនាំគ្នាដាក់សពអ្នកស្រីប្រពន្ធលោកសុគន្ធា នឹងបុត្រតូចៗ ទាំងពីរលើរថយន្តកងទ័ព ដឹកយកមកទីតាំងនៃខេត្តកំពង់ធំ ដើម្បីរៀបហែរហមឱ្យបានឧឡារិកក្រោមអធិបតីភាពនៃលោកប្រមុខខេត្ត ហើយដើម្បីជូនមន្ត្រីជាន់ខ្ពស់នេះថ្លែងបាឋកថាសរសើរនូវគុណសម្បត្តិ នឹងវិរកិច្ចនៃលោកសុគន្ធាចំពោះមហាជនទូទៅ ។

# ជំពូក៤

## លោក សាវ័ណ្ណ

កន្លងពីព្រឹត្តិការណ៍នោះមកបានពីរថ្ងៃ លោកនាយកក្រសួងប៉ូលីសជាតិនៅទីក្រុងភ្នំពេញ ដែលកំពុងពិនិត្យរាយការណ៍យ៉ាងវែងរបស់លោកកុម្មីស្សែរប៉ូលីសជាតិកំពង់ធំ ដំណាលអំពីរឿងលោកសុគន្ធា ។ លោកអានមិនទាន់ចប់ផងក៏មានបណ្ណទូតម្នាក់គោះទ្វារចូលមក ហើយលាត្រដាងសៀវភៅបញ្ជូនពុងស្រោមសំបុត្របិទមុខមួយមកជូនលោក ។ លោកក្រឡេកឃើញនៅលើខ្នងមានចារដាក់ថាការសម្ងាត់ ។ លោកចុះហត្ថលេខាក្នុងសៀវភៅ ហើយទទួលយកស្រោមនោះមកបើកមើល ឃើញលិខិតពីរច្បាប់ផ្ញើពីទីស្ដីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមក ។

លុះលោកអានរាយការណ៍នៃកូនបង្គាប់លោករួចហើយៗបែរមកអានលិខិតថ្មីទៀត លោកក៏ប្រើបណ្ណទូតហៅលោកឱ្យអញ្ជើញលោកអធិការប៉ូលិសជាតិគ្រប់រូបអង្គុយនៅមុខលោក ។

– លោក ! ឥឡូវមានបង្គាប់ពីឯកឧត្ដមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមក (លោកនាយកប៉ូលីសជាតិប្រកាសប្រាប់) បញ្ជូនទាំងសំបុត្រអនាមិកមួយច្បាប់ដោយសម្ងាត់មកខ្ញុំ សំបុត្រនោះមានសេចក្ដីថា លោកសុគន្ធាមិនមែនស្លាប់ទេ គឺលោកបានលើកកូនក្រមុំឱ្យទៅអាមេចោរហើយសម្លាប់ប្រពន្ធនឹងកូនតូចៗចោល ដើម្បីចូលព្រៃប្លន់ដណ្ដើមយកទ្រព្យគេ



សម្លាប់អ្នកស្រុកស្លូតត្រង់ឥតប្រណី ព្រមទាំងថាកាលនៅធ្វើការក្នុងស្រុកមន្ត្រីកាន់អំណាចនេះ ផ្សំគំនិតនឹងពួកចោរដែលលោកចាប់បាននឹងប្រមូលភស្តុតាងបានគ្រប់សព្វមក ហើយលោកមិនបញ្ជូនទៅតុលាការទេ បែរជាបើកឱ្យទៅផ្ទះវិញដោយស្រួលទុកឱ្យវាទៅប្លន់ធ្វើបាបអ្នកស្រុកហិនហោចអស់ បើពុំនោះសោត លោកធ្វើផ្ទុយពីនេះទៅវិញ គឺទៅចាប់យកតែអ្នកស្រុកសុចរិតមកវាយដំច្រំធាក់ ឃុំឃាំងដាក់ច្រវាក់ជាច្រើនថ្ងៃ ទើបបញ្ជូនទៅរាជការមុខក្រសួង ។

– ចុះខ្ញុំបាទឃើញក្នុងសារពត៌មាន «កម្ពុជា» (អធិការម្នាក់សួរ) គេដំណាលថាមានអគ្គាក់សាលាស្រុក សម្លាប់បានលោកចៅហ្វាយស្រុកព្រមទាំងសម្លាប់ប្រពន្ធកូនលោក នឹងចាប់កូនក្រមុំលោកទៅផង ម្ដេចក៏សំបុត្រនេះមកពោលខ្សៅទៅវិញ ?

– ទេពុំសមទេ (អធិការម្នាក់ទៀតជូនមតិ) មិនដែលមានមន្ត្រីណាចិត្តអាក្រក់បែបនេះទេ លើកកូនក្រមុំឱ្យគេហើយសម្លាប់ប្រពន្ធឯងសម្លាប់កូនឯងទៀតនោះ....

– មិនមែនទេ (លោកនាយកឆ្លើយកាត់) គឺជាស្នាដៃមនុស្សចិត្តឃោរឃៅ ដែលវាធ្លាប់តែជញ្ជក់ឈាមរាស្ត្រតាំងពីដើមមក លុះឃើញលោកសុគន្ធាទៅដល់ កាន់យុត្តិធម៌ត្រឹមត្រូវ ហើយបង្ក្រាបមនុស្សទុច្ចរិតរាំងផ្លូវអកុសលរបស់វាក៏វាខឹងវា- វាព្យាបាទដូច្នេះទៅ ។ លោកសុគន្ធាស្លាប់ហើយវានៅតែមិនសុខចិត្តទៀត ប្រហែលជាវាមិនសុខចិត្តត្រង់គេសរសើរពីគុណសម្បត្តិលោកនៅពេលក្រោយមរណភាពផងក៏មិនដឹង.....

ឯខ្ញុំដែលសុំអញ្ជើញអស់លោកមកជួបជុំក្នុងពេលនេះគឺចង់សួរមើលក្រែង មានលោកណាចង់ចេញទៅធ្វើបេសកកម្មដល់ទីកន្លែងស្រុករវៀងតាមបង្គាប់ឯកឧត្តមរដ្ឋមន្ត្រីដើម្បីស៊ើបរកការពិតក្នុងស្រុក ប៉ុន្តែបើគ្មានលោកណាចង់ទៅទេ ក៏ហើយទៅ ព្រោះខ្ញុំយល់ឃើញថា មិនជាការមានប្រយោជន៍ប៉ុន្មានទេ ត្បិតលោកកុម្មីស្សែរកំពង់ធំ នឹងអស់លោកឯទៀតបានទៅស៊ើបអង្កេតខ្ទិចខ្ទីរួចអស់ទៅហើយ ។

ក្នុងពេលនោះលោក «សាវ៉ណ្យ» ក៏ជាអធិការម្នាក់មានវ័យក្មេងជាងគេក្នុងចំណោមនោះ គ្មាននិយាយស្តីអ្វីនឹងគេទេ ខំតែឱនមុខជ្រុបភ្នែករលីងរលោងៗ ។ លោកចង់តែងើបឡើងសុំខ្លួនទៅ ប៉ុន្តែបង្ក្រប់ចំណង់នេះទៅវិញនឹកថាការអ្វីៗត្រូវតែគិតឱ្យវែងឆ្ងាយសិន ។ គឺអ្នកកំឡោះនេះហើយដែលបានឱ្យឪពុកម្តាយដែលនៅកំពង់ធំ ចូលស្តីដណ្តឹងនាងគន្ធពិដោរដល់លោកសុគន្ធា កាលលោកនេះនៅធ្វើជាភូឈួយខេត្តកំពង់ធំនៅឡើយ ។ លោកអធិការមានស្តាយនឹងនឹកឆ្ងល់ធំណាស់ដោយមិនដឹងជាលោកសុគន្ធាគិតយ៉ាងម្តេច បានជាមិនព្រមលើកកូនស្រីមកឱ្យខ្លួនសោះប្រហែលជាលោកសុគន្ធាស្អប់មុខ ក្រសួងគិញដែលខ្លួនធ្វើសព្វថ្ងៃនេះទេដឹង ឬមួយក៏មកពីនារី កូនលោកមិនត្រូវចិត្តនឹងខ្លួន ? លោកសាវ៉ណ្យគិតមិនធ្លុះធ្លាយសោះព្រោះលោកនៅមានអនុស្សាវរីយច្រើន អំពីលោកចៅហ្វាយសុគន្ធា ។ កាលដែលខ្លួនពុំទាន់ចូលមកធ្វើការក្នុងប៉ូលិសនេះខ្លួនបានធ្វើជាលេខាធិការនៅសាលាខេត្តក្រោមបង្គាប់ផ្ទាល់នៃលោកសុគន្ធាៗ បានទាំងនិយាយទូន្មានដោយស្មោះត្រង់ញ៉ាំងខ្លួន



ឱ្យមកសុំធ្វើការក្នុងប៉ូលិសវិញព្រមទាំងបានបង្ហាញផលប្រយោជន៍អំពីប៉ូលិសនេះយ៉ាងណាៗផង ពុំគួរអ្វីលោកស្អប់ក្រសួងប៉ូលិសដូច្នេះសោះ ។ កូនស្រីលោកសោតក៏បានស្គាល់ខ្លួនជាក់លាក់ណាស់ ដោយកាលពីប្រាំមួយឆ្នាំមុន ខ្លួនបានទៅធ្វើជាចាងហ្វាងរងនៃសាលាយុវជននៅទន្លេបាទិក្នុងខេត្តតាកែវ បាននាំនាងគន្ធពិដោរ ដែលកាលនោះធ្វើជាចាងហ្វាងរងនៃសាលាយុវនារី ជិះទូកលេងក្នុងទន្លេ ។ មានជួនកាលជិះតែពីរនាក់នឹងនាងក្នុងទូកមួយកណ្តាលជលសាផង ។ បានជាឆ្លៀតឱកាសធ្វើដូច្នេះបានមកពីសាលាយុវបុរសដែលបង្ហាត់ពួកនាយយុវជនទាំងឡាយក្នុងព្រះរាជាណាចក្រនោះ សង់នៅជិតគ្នានឹងសាលាយុវនារីដែលមានឧត្តមគតិដូចគ្នា។ មួយនៅក្នុងចំការដូងមួយនៅជិតប្រាសាទបាទី ។ ចាងហ្វាងធំនៃសាលាទាំងពីរបានរាប់អានគ្នាណាស់ ព្រមទាំងបាននាំសិស្សរៀងខ្លួនឱ្យទៅស្គាល់គ្នា ធ្វើការជាមួយគ្នាម្តងៗ ជាសាធារណប្រយោជន៍ផង ។

លុះលោកនាយកបញ្ចេញប្រសាសន៍ថា «អញ្ជើញលោកទៅសិនចុះចាំខ្ញុំគិតមើលបន្តិចទៀត» ហើយពួកអធិការទាំងអស់លាចេញមកកន្លែងធ្វើការរៀងខ្លួន លោកសាវ៉ណ្យក៏ថយមកជាមួយនឹងគេដែរ ។ ពេលយប់នោះអធិការសាវ៉ណ្យដែលមានទឹកមុខស្រពត់ស្រពោនតាំងពីព្រឹកមក ពុំបានដើរទៅលេងឯណាដូចជនភ្នំពេញឯទៀតឡើយ ។ លោកអង្គុយក្នុងផ្ទះតែម្នាក់ឯង រកដោះស្រាយបញ្ហាដែលប្រទាក់គ្នាស្មុគ្រស្មាញ តែមុខលោកៗ រកមើលអ្វីក្រៅពីនេះពុំឃើញឡើយ ។ បញ្ហាអ្វីខ្លះទៅ? លោករករាប់មិនអស់ ។ ក្រៅពីរកហេតុដែលគេផ្តាច់កូនក្រមុំពីបំណងឯករបស់

លោក លោកមានព្រួយបារម្ភ ពីជោគវាសនារបស់នាងកញ្ញាដែលធ្លាប់មានចំណេះវិជ្ជា គ្រាន់បើនឹងគេដែរ ធ្លាប់មានសីលធម៌ល្អប្រពៃនឹងគេដែរ នោះបែរជាឱ្យពួកចោរព្រៃធ្វើបាបបង្អាតចំនួនពលរដ្ឋស្ត្រីម្នាក់ក្នុងកម្ពុជា ។ ស្តាយណាស់ៗ ។ ណាមួយនាងជាចំណុចដ៏សំខាន់ ដែលមនោសញ្ចេតនាស្នេហារបស់ខ្លួន បានបាញ់តម្រង់ទៅចំឃ្លូវមកហើយម្លេះ នាងនៅកំព្រាតែម្នាក់ឯង កណ្តាលហ្វូងចោរកនរណាជាពំនាក់ពុំបានសោះ ។ ម្តាយក៏ស្លាប់ ឪពុកក៏ស្លាប់ ។ មិនតែប៉ុណ្ណោះមរណភាពថែមទាំងផ្តាច់ប្អូនប្រុសនាងទាំងពីរ ពីដួងចិត្តនាងផង ។

ខ្វល់ក្នុងចិត្តពេកទៅអធិការសាវ៍ណ្យខំសង្កត់ស្មារតីក្រោកទៅបើកភ្លើងវិទ្យុដែលដាក់លើទូចាន ហើយមួលដោយព្រាវៗ ពុំដឹងជាចង់ស្តាប់





អ្វីជាអ្វីទេ ។ លោកមួលចុះមួលឡើងញ៉ាំងឱ្យតែឧគ្ឃោសនស័ព្ទនេះបញ្ចេញសូរដូចជាគេវាយស្គរគេហួចឱ្យគេផ្ទុកញ្ចេ ឬស្រែកទះតុលាយឡំគ្នាមិនដឹងអ្វីជាអ្វីខ្លះ ។ លោកឈរយូរពេកកើតរួយជើងក៏ដាក់ចំប៉ុស្តិ៍ សៀម គ្រាន់នឹងវាច្រៀងឱ្យស្តាប់ ។ ប៉ុស្តិ៍សៀមច្រៀងមិនបានប៉ុន្មាន ក៏តាំងថ្លែងអធិប្បាយយ៉ាងវែងរកយល់ផងពុំបាន ។ លោកក្រោកពីកៅអី ទៅមួលបន្តិចៗ ចុះឡើងៗរកមើលក្រែងមានប៉ុស្តិ៍ណាទៀតដែលគេ លេងភ្លេងនឹងច្រៀងពីរោះៗគ្រាន់បានស្បើយពីកង្វល់ចិត្តលោកមួយឱ្យខ្ពស់ ដល់ទៅលេខប៉ែតសិបក៏ស្រាប់តែមានសព្ទមួយយ៉ាងខ្សោយស្រែកចេញ មកដោយពាក្យដដែលៗថា...ជួយផង...ជួយផង...សុទ្ធា...សុទ្ធា...រួចក៏ អស់ទៅ ។ លោកចាំបន្តិច ក៏ឮទៀត...ជួយផង...ជួយផង...គធា... រួចពីនេះក៏ឮខ្យល់បក់យ៉ាងខ្លាំងគ្មានបាញ់ចំសូរស័ព្ទអ្វីទៀតសោះ ។ លោកឈរចាំចាញ់ចំណោះក៏បិទភ្លើងវិទ្យុហើយមកអង្គុយជក់បារីនៅរានហាល ខាងមុខផ្ទះ ។

ស្ទី? សធា... (លោករកនឹក) សធាឬក៏គធា? ពេលម៉ោងប្រាំបួនយប់ម្តេចក៏មាននិយាយខ្មែរ? និយាយខ្មែរអីក៏នៅរលកធាតុអាកាសពេស់ប៉ែតសិបម៉ែត្រ ។

ក្នុងយប់នោះ លោកនិទ្រាមិនជាលក់ប៉ុន្មានទេ ។ ព្រឹកឡើងកាលបើទៅដល់ ប៉ុយរ៉ូធ្វើការហើយ អធិការសាវ័ណ្យចូលទៅជួបលោកនាយកប៉ូលីសជាតិមិនបង្អង់សោះ ។

លោកៗពិតឬ? (លោកនាយកសួរបញ្ជាក់អំពីសំដីអធិការ ដែលសារសព្ទជិរាបលោកអំពីការណ៍ដែលមានរឿងពីយប់មិញ) ។

– ទានពិតណាស់ មិនច្រឡំទេ ។

– បើដូច្នោះ តាមខ្ញុំស្មានថា សធាឬគធានោះ មានតែឈ្មោះលោកសុគន្ធា ប៉ុន្តែសុគន្ធាឯណាមកស្រែកហៅដូច្នេះ? លោកសុគន្ធាស្លាប់ទៅហើយ មានភស្តុតាងបង្ហាញច្បាស់ណាស់ ។

– ទានក្រែងតែពួកទាហាននៃសៃន្យានុភាពខ្មែរ គេរៀននិយាយឆ្លងឆ្លើយគ្នាតាមឃោសនសព្ទទេក៏មិនដឹង ។

លោកនាយកប៉ូលីសទាញទូរសព្ទមកនិយាយសួរទៅក្រសួងការពារប្រទេស១ ឆ្លើយមកវិញថា គ្មានទាហានណាហាត់របៀបនោះទេ ហើយក្រុមទាហានខ្មែរពុំទាន់មានប៉ុស្តិ៍វិទ្យុសម្រាប់ផ្សាយដំណើងដ៏បរិបូណ៌នៅឡើយផង ។

– ឃី ! ខ្ញុំឆ្ងល់ណាស់ បើសិនជាលោកសុគន្ធានៅរស់មែនប្រហែលជាដូចសំបុត្រអនាមិកៈនោះហើយ...អុះមែន ! មិនដូចសុទ្ធណាស់ទេ បើលោកនៅរស់មែនប្រហែលជាមានគ្រោះថ្នាក់អ្វីមួយយ៉ាងធំហើយមើលទៅ បានជាស្រែកបំពាវនាវឱ្យគេជួយដល់ទីនេះ ។ ធ្វើម្តេចបានទៅស៊ើបដល់ទីកន្លែងម្តងទៀតហ្ន៎ ? ចុះបើពួកព្រៃវាស្ទប់ពួកក្រុមយើងយ៉ាងនេះធ្វើម្តេចទៅកើត ? មានភ្នាក់ងារណាហ៊ានទៅ? ទៅស៊ើបម្តេចបានការ ?

– ការណ៍នេះនឹងអង្កេតរកឃើញក៏យូរដែរ ខ្ញុំបាទបើកុំតែយូរ ដូច្នេះកុំអីខ្ញុំបាទចង់សុំខ្លួនទៅមិនរួញរា ត្បិតខ្ញុំបាទចិត្តខុសគេណាស់ កាលបើឮថាមានពលរដ្ឋណាធ្វើការស្មោះត្រង់នឹងប្រទេសជាតិចេះជួយ សង្គ្រោះជនជាតិ



ខ្មែរដូចគ្នា ដែលក្រីក្ររងទុក្ខវេទនា ហើយបែរទៅជា បានទុក្ខដោយសារអំពើអកុសលទៅវិញនោះ ខ្ញុំបាទចង់តែទៅសងសឹក ជួយបងប្អូនកូនក្មួយគេតែម្តង គ្មានគិតដល់អាយុជីវិតរបស់ខ្ញុំបាទទេ ។

– ទៅភ័យអ្វីត្រង់យូរ បើលោកប្រាកដជាចង់ទៅចាំខ្ញុំចេញសំបុត្រឱ្យដើរតាមត្រូវការ ប៉ុន្តែខ្ញុំដូចជាឆ្ងល់ដែរលោកទៅដោយរកមធ្យោបាយយ៉ាងណាទៅ ?

– ទានប្រាសមិនទាន់ឃើញទេ ចាំទៅស៊ើបមើលម្តងបន្តិច១ម្នាក់ឯងសិនបើត្រូវការអ្វី១ទៀតខ្ញុំបាទនឹងសុំជាក្រោយ ចិត្តខ្ញុំបាទគិតនឹងទៅតាមយកលោកសុគន្ធា នឹងកូនស្រីលោកពីកណ្តាប់ដៃចោរមកវិញផងបើជាលោកនៅរស់ឡើយ ។

*****

## ជំពូក៥

## ការសន្ទនា ជាមួយលោកកុម្មីស៊ែរ

លោកអធិការសាវ៉ែណ្យចេញទៅតែម្នាក់ឯងដល់ខេត្តកំពង់ធំ ក្នុងពេលរសៀលថ្ងៃនោះ ។ លោកបានចូលសន្ទនានឹងលោកកុម្មីស៊ែរប៉ូលីសជាតិ ប្រចាំខេត្តនោះ ។

– អញ្ជើញមកលោក ! (លោកកុម្មីស៊ែរទទួលលោកអធិការដែល





គោះទ្វារចូលហើយហុចសំបុត្រមួយមក) ឱ ! លោកអញ្ជើញមកអង្កេតរឿងនៅរវៀងឬ ? អង្កេតរកអ្វីទៀតទៅលោក ? សំបុត្រនេះលោកនាយកលោកសុំឱ្យខ្ញុំជួយឱ្យអស់ដៃ តើត្រូវខ្ញុំជួយលោកនូវរបៀបយ៉ាងណាខ្លះទៅ?

– ទេ ! លោកកុម្មីស៊ែរ (លោកសាវ៉ែណ្យឆ្លើយ) គោលបំណងនៃបេសកម្មយើងលាយឡំគ្នាណាស់ ហេតុនេះហើយបានជាខ្ញុំបានជំរាបសុំលោកនាយកមកឱ្យបានយូរបន្តិច ឯកិច្ចដែលត្រូវការនោះ គឺរកមើលមួយ តើលោកសុគន្ធាស្លាប់មែនឬពុំមែន? ពីរបើពុំមែនស្លាប់ទេ តើទៅទីណាហើយ? បីទៅដោយចិត្តឯងចោលការរាជការឬក៏ទៅដោយគេបង្ខំ? បួនមានគំនិតអាក្រក់យ៉ាងម្ដេចខ្លះនឹងរាជការផែនដី ? ប្រាំគឺរកឱ្យដឹង តើលោកសុគន្ធាមានធុរៈឬគ្រោះថ្នាក់យ៉ាងណាយើងនឹងទៅជួយ, ប្រាំមួយគឺ..

– យី ! ខ្ញុំឆ្ងល់ណាស់ ប្រហែលជាលោកនាយកពុំទាន់បានទទួលរាយការណ៍យ៉ាងវែងរបស់ខ្ញុំទេមើលទៅ រាយការណ៍ខ្ញុំធ្វើត្រឹមត្រូវណាស់ ឆ្លើយនឹងខ ដែលលោកត្រូវរកទាំងអស់នេះហើយ បើប្រសិនជាលោកនាយកបានអានហើយលោកប្រហែលជាមិនបាច់ឱ្យលោកអញ្ជើញមកទៀតទេ រាយការណ៍នោះធ្វើគួរឱ្យជឿបានណាស់ ព្រោះខ្ញុំបានទៅដល់ទីកន្លែងជាមួយនឹងអ្នកជំនាញស៊ីវិលទាំងអស់ បានជំនុំគ្នាមានមតិស្របគ្នា ។

– រាយការណ៍លោក ខ្ញុំពុំបានឃើញម្ដេចទេ ប៉ុន្តែលោកនាយកបានទទួល នឹងអានរួចហើយ ព្រោះលោកបានប្រាប់ខ្ញុំ ប៉ុន្តែមានការណ៍ចំឡែកពីរយ៉ាងដែលធ្វើឱ្យពួកក្រុមប៉ូលិសយើងបែកខួរក្បាល ។

– បែកខ្ញូវពីអ្វីទៅ ?

លោកសាវ័ណ្ឌ្យដំណាលជំរាបបលោកកុម្មីស្ស៊ែរពីសំឡេងអាថ៌កំបាំងនៃវិទ្យុនិងអំពីសំបុត្រអនាមិក:សព្វគ្រប់ ។

– ឆ្កួត ! អាអ្នកសរសេរជាមនុស្សឆ្កួតណាំ ! វាស្មានថារាជការ ធំជឿតាមដំណឹងអកុសលទាំងនោះឬ ? (មុខលោកកុម្មីស្ស៊ែរឡើង ក្រហមដោយឈាមកំហឹងច្រាលឡើងមកលើខ្ពាំងពេក) ។

– ហើយវាថា លោកសុគន្ធាចិត្តអាក្រក់នឹងបណ្តាជនណាស់ (លោកសាវ័ណ្ឌ្យនិយាយប្រាប់បន្ថែមទៀត)

– ខ្ញុំទៅអង្កេត ក៏គ្មានឮអ្នកស្រុកណានិយាយអាក្រក់អ្វីពីលោកសោះ? ខ្ញុំមើលឃើញហើយមនុស្សដែលសរសេរសំបុត្រនេះ ប្រហែលជាវានេះហើយដែលព្យាបាទលោកសុគន្ធា លោកសុគន្ធាវិនាសដោយសារវានេះហើយ ប៉ុន្តែឯងនិយាយដូច្នេះទៅដូចជាសាហាវណាស់ ពុំទាន់អង្កេតឃើញភស្តុតាងអ្វីផងប្រញាប់តែមុសាគេ ។

– មើលទៅប្រហែលជានៅរស់ទេ ហេតុនេះហើយបានជាមានសម្រែកហៅក្នុងវិទ្យុ ។

– ដឹងអីថា ! ប៉ុន្តែបើលោកគ្រាន់តែសន្និដ្ឋានថានៅរស់ប៉ុណ្ណោះ បានឯត្រង់ចង់ដឹងថាលោកហៅពីទីណាមកនោះប្រហែលជាពិបាកបន្តិចហើយ ។



– ស្តាយណាស់ ! បើសិនជាកាលខ្ញុំចាក់វិទ្យុនោះខ្ញុំដឹងកន្លែងបានហើយដាក់ម្ជុលវាចំទីនោះតាំងពីមុនពេលនោះបន្តិចប្រហែលជាឮឱ្យដំណឹងពីទីកន្លែងដែលនិយាយមកឬ ពតិមានអ្វីទៅទៀតហើយតែឡើយចុះបើបានជាហួសដូច្នេះទៅហើយចិត្តខ្ញុំៗចង់តែទៅធ្វើអង្កេតដល់ស្រុករវៀង ម្តងទៀត ព្រោះកាលដែលលោកអញ្ជើញទៅនោះ វាកំពុងតែតក្កហលពេកហើយគេច្រើនខ្លាចអំណាចពួកចោរផង ឥឡូវប្រហែលជាអ្នកស្រុកឈប់ខ្លាចទៅហើយមើលទៅ...រួចចុះសព្វថ្ងៃនេះបាននរណាមើលការខុសត្រូវក្នុងស្រុកជាជំនួសលោកសុគន្ធា ?

-លោកចៅហ្វាយខេត្តបានចាត់លោកបាឡាត់ខេត្តវង្គីរិទ្ធិឱ្យទៅហើយបានឱ្យទាហានមួយកងសំរាប់បំរើលោកនេះផង មិនអីទេ បើលោកចង់អញ្ជើញទៅចាំខ្ញុំជូនទៅ សុំលោកទៅជួបនឹងលោកចៅហ្វាយខេត្តជំរាបលោកអំពីដំណើរយើងសិន រួចសុំឱ្យលោកចាត់កងទាហានឱ្យជូនយើងទៅ

លោកកុម្មីស្ស៊ែរបិទសៀវភៅនឹងសំណុំរឿងទាំងឡាយដែលនៅលើតុ ហើយក្រោកឡើងនាំលោកអធិការជិះរថយន្តទៅសាលាខេត្តភ្លាម ។

ម៉ោងមិនទាន់ដល់ដប់មួយផង គេឃើញលោកកុម្មីស្ស៊ែរនឹងលោកអធិការ បានរៀបដំណើរចេញពីកំពង់ធំគ្មានយឺតយូរ ។

អ្នករាជការប៉ូលិសជាតិពីរនាក់នេះជិះឡានហ្ស៊ីបពីមុខកាម្មុងទាហានដោយមានភ្នាក់ងារប៉ូលិសជាតិពីរនាក់អមផង ។

– លោកមានធ្វើផែនការទុកជាស្រេចហើយនៅ? ពេលយើងតិចណាស់ បើនឹងនៅយូរក្នុងស្រុកព្រៃនេះទៅឃើញថាក្រែងគ្រោះថ្នាក់ (លោកកុម្មីស៊ែរសួរ)

– មិនអីទេលោក? (លោកអធិការតប) គង់តែបានរហ័សទេ យើងទៅរកដំបូង គឺរកអ្នកនិពន្ធសំបុត្រអនាមិកៈ បើរកឃើញឬមិនឃើញ គង់តែលេចផ្លូវឯទៀតជាក្រោយដើម្បីនាំយើងឱ្យទៅដល់ការពិតទេ ។

– លោកមានយកមកដែរ? សំបុត្រនោះ?

នេះលោក...(លោកសាវ័ណ្យត្រដាងបង្ហាញលិខិតនោះផង ទប់វត្ថុនេះនឹងកម្លាំងខ្យល់ដែលចូលតាមចន្លោះកញ្ចក់រថយន្តមកដណ្ដើមយកទៅបោះចោលផង លោកកុម្មីស៊ែរដែលរវល់កាន់ចង្កូត រកឆ្លៀតងាកមកមើលបញ្ជាក់អក្សរក្នុងក្រដាសសឹងពុំបាន ។

– អក្សរវាយម៉ាស៊ីនផង ? ខ្ញុំរកនឹកមិនឃើញទេ មិនដឹងជាអក្សរម៉ាស៊ីនក្រសួងណាទេហ្នឹង ! ។

ម៉ោងដប់ពីរកន្លះ ក្បួនជូននេះបានទៅដល់ផ្សាររវៀង. ចូលចតនៅមុខសាលាស្រុក ។ ពួកអ្នករាជការសាលាស្រុកបានចុះទៅផ្ទះរៀងខ្លួនអស់ទៅហើយ ។ មានតែជនម្នាក់ចុះពីគេហដ្ឋានបៀតនោះ មាឌមិនជាខ្ពស់ប៉ុន្មានសម្បុរខ្មៅស្លៀកពាក់ខោអាវពីហ្សាម៉ាឆ្នូតពណ៌ក្រហមឈាមជ្រូករុំកនឹងកន្សែងមកពីស្រុកបារាំង ដើរមកទទួលមន្ត្រីក្នុងក្រសួងប៉ូលីសទាំង



ពីរនាក់ ដោយមានទឹកមុខញញឹមពព្រាយ ប៉ុន្តែពុំមានបិទបាំងនូវចិត្តងឿងឆ្ងល់សោះ ។

– អញ្ជើញមកលោកកុម្មីស៊ែរ (បុរសនេះស្រែកពីចម្ងាយ)

– លោកចៅហ្វាយ ! ខ្ញុំសុំបង្ហាញនេះលោកសាវ័ណ្យអធិការប៉ូលីសជាតិនៅភ្នំពេញ (លោកកុម្មីស៊ែរនិយាយទៅជនដែលមកនោះ) ។

– ខ្ញុំមានសោមនស្សនឹងបានស្គាល់លោកអធិការ (ហើយងាកទៅសួរលោកកុម្មីស៊ែរវិញ) លោកអញ្ជើញមកមានការអ្វីលោក?

– បាទលោកអធិការត្រូវការមកស៊ើបអង្កេតរឿងផ្សេងៗអំពីលោកសុគន្ធា....

– អំពីបេសកម្មខ្ញុំនេះ (លោកសាវ័ណ្យបន្ថែមលើប្រសាសន៍លោកកុម្មីស៊ែរ ហើយដកយកសំបុត្រចាត់លោកនាយកប៉ូលិសជាតិមកបង្ហាញ) ខ្ញុំមិនដឹងជាតម្រង់ទៅឯណាខ្លះទេ ខ្ញុំធ្វើតម្រូវតែចំណង់លោកនាយករួចផុតកិច្ចខ្ញុំហើយ ។

– លោកអញ្ជើញផ្លាស់សំលៀកបំពាក់សិនទៅ! ខ្ញុំបានលោកអញ្ជើញ មកនេះ ដូចជាមានកក់ក្ដៅច្រើន ព្រោះខ្ញុំមិនធ្លាប់កាន់ការជាចៅហ្វាយស្រុកនេះសោះ ហើយបារម្ភក្រែងតែពុំបានសន្តិភាព ណាមួយខ្ញុំពុំសូវ ប្រសប់ក្នុងការចំបាំងសោះ ។

លោកវឌ្ឍិរិទ្ធិ ចៅហ្វាយស្រុករវៀងអញ្ជើញមន្ត្រីដែលទើបនឹងមកដល់ក្នុងសាឡុង ហើយក៏សុំទោសដកឃ្លាចេញមកចាត់ការឱ្យពួកប៉ូលិស

ស្រុកធ្វើភោជនាហាររៀបចំទទួលពួកទាហាននៃក្បួនជូន ដោយលោកបានរាប់ចំនួនរួចជាស្រេចទើបចូលមកធ្វើសន្ទនាការក្នុងសាឡុងតទៅទៀតដើម្បីកំដរភ្ញៀវ ។

សុំលោកពិសាភេសជ្ជៈលេងសិនទំរាំដល់ពេលបាយ ( សំដីលោកចៅហ្វាយ ) ។

សុំទោស ! នែ...ប៉ូលិសជិនាន់លោកសុគន្ធានៅប៉ុន្មាននាក់? ( លោកកុម្មីស្សែរសួរ ) ។

គ្មានទេលោកកាលនោះ ឮថាចោរវាបាញ់ស្លាប់នៅនឹងកន្លែងប្រាំនាក់សល់ប៉ុន្មានវាចាប់យកទៅទាំងអស់ ប៉ុន្តែដោយប៉ូលិសពីរនាក់ រត់រួចមកវិញគឺដោយក្រាញ់នឹងដោយកញ្ចុះឪពុកខ្ញុំ ។

អុះ! ដោយកញ្ចុះជាឪពុកលោក? ( លោកកុម្មីស្សែរសួរ ) ។

បាទឪពុកខ្ញុំ ប៉ុន្តែគ្មានអ្នកណាស្គាល់ទេ ព្រោះខ្ញុំបែកពីឪពុកម្តាយទៅ នៅនឹងឪពុកធំឯភ្នំពេញយូរហើយៗឪពុកខ្ញុំមិនដែលហៅខ្ញុំចំឈ្មោះតាមសំបុត្រកំណើតទេ គាត់ហៅតែអាក្លាញៗប៉ុណ្ណោះ ខ្ញុំមកធ្វើការជាបាឡាត់ខេត្តនៅកំពង់ធំនេះ ទើបនឹងបានប្រហែលប្រាំមួយឬប្រាំពីរខែប៉ុណ្ណោះទេ ។ រួចចុះអំពីពួកប៉ូលិសដែលចោរចាប់ទៅនោះលោកមានស៊ើបបានការអ្វីខ្លះដែរ? ខ្ញុំបានស៊ើបៗទៅដឹងថាវាសម្លាប់អស់ច្រើនណាស់ហើយ ប៉ុន្តែដំណឹងនេះពុំបានច្បាស់ទេព្រោះមានប៉ូលិសទាហានតិចពេកពុំទាន់បានធ្វើរាយការណ៍អ្វីប្តឹងទៅខេត្តសោះ ។



– ដោយប៉ូលិសទាំងពីរនោះនៅនឹងនេះទេឬ ?

– ស្តាយពេក ឪពុកខ្ញុំ បានទៅធ្វើទស្សនាការផុតពីព្រឹកមិញនេះឯដោយក្រាញ់នោះពីថ្ងៃមុនវាផឹកស្រាស្រវឹងខ្លាំងពេក បានកន្ទ្រាក់សេះអ្នកស្រុកជិះទៅក្រៅផ្សារមិនដឹងរបង់ទៅទីណាទេ ស្រាប់តែពីព្រឹកមិញនេះលោកចៅហ្វាយស្រុកសណ្តាន់ឱ្យដំណឹងមកថា រើសបានអសុភវាអណ្តែតទឹកស្ទឹងសែន ដាច់ក្បាលបាត់ទៅហើយ គេស្គាល់វាដោយសំលៀកបំពាក់រាជការនឹងមានឃើញកាត្រវាក្នុងហោប៉ៅខោ ។ ខ្ញុំកំពុងតែឱ្យលោកស្មៀនសាលាព្រាងរាយការណ៍ឱ្យដំណឹងទៅខេត្ត ។

✱✱✱✱✱